01108440

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**ឯកសារ D120/1/1/2**

***តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ១៨)

| | | |
|---|---|---|
| ចំពោះមុខ: | **ចៅក្រម ប្រាក់ គឹមសាន** | **ប្រធាន** |
| | **ចៅក្រម** Olivier BEAUVALLET | |
| | **ចៅក្រម នីយ ថុល** | |
| | **ចៅក្រម** Steven J. BWANA | |
| | **ចៅក្រម ហួត វុទ្ធី** | |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17/06/2015
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ:**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះញត្តិរបស់មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ**

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Nicholas KOUMJIAM

**<u>សហមេធាវីការពារក្តី មាស មុត</u>**

អាង ឧត្តម

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី:</u>**

| | |
|---|---|
| ហុង គីមសួន | Ferdinand DJAMMEN NZEPA |
| គីម ម៉េងឃី | Nicole DUMAS |
| ម៉ុច សុវណ្ណារី | Isabelle DURAND |
| | Françoise GAUTRY |

Michael G. KARNAVAS

សំ សុគង់
ទី ស្រ៊ីនណា
វ៉ែន ពៅ
Philippe CANONNE
Laure DESFORGES

Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់មាស មុត ប្រឆាំងទៅនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតចំពោះញត្តិរបស់គាត់សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ" ដែលបានដាក់កាលពីថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ("បណ្តឹងឧទ្ធរណ៍")[1]

## ក. សាវតារ

1. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី នៅពេលនោះ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងកងទ័ពបដិវត្តកម្ពុជា ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ") ទៅសហចៅក្រមស៊ើបអង្កេត ដោយស្នើឲ្យបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការទៅលើបទឧក្រិដ្ឋកម្មមួយចំនួនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តិដោយ មាស មុត រួមជាមួយនឹងជនសង្ស័យម្នាក់ទៀត[2]។

2. នៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានចេញសេចក្តីប្រកាសព័ត៌មានមួយដែលបានលើកឡើងថា នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ គាត់បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលមានគោលដៅចម្បងដើម្បីលុបបំបាត់ភាពមិនច្បាស់លាស់អំពីវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយស្នើសុំសហចៅក្រមស៊ើបអង្កេតឲ្យបញ្ចូលបទឧក្រិដ្ឋកម្មបន្ថែមទៀតទៅក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម")[3]។

---

[1] ឯកសារ D120/1/1/1។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លើកទីពីរ ពាក់ព័ន្ធកងទ័ពបដិវត្តកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារ D1។ ការជូនដំណឹងពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ របស់សហព្រះរាជអាជ្ញាស្តីទីអន្តរជាតិ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩, ឯកសារ D1/1។

[3] សេចក្តីប្រកាសព័ត៌មាន, សេចក្តីប្រកាសរបស់សហព្រះរាជអាជ្ញាអន្តរជាតិ Nicholas Koumjian ពាក់ព័ន្ធសំណុំរឿង ០០៣, ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ គួរកត់សម្គាល់ថា នៅពេលដាក់បណ្តឹងឧទ្ធរណ៍ មាស មុត មិនមានសិទ្ធិចូលពិនិត្យមើលសំណុំរឿងឡើយ រួមទាំងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

3. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤ មាស មុត បានដាក់ញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចេញពីសំណុំរឿង ដោយផ្អែកលើមូលដ្ឋានថា "ក. នីតិវិធីដោះស្រាយវិវាទ មិនអនុញ្ញាតឱ្យដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដកចេញនូវភាពមិនច្បាស់លាស់ទាំងឡាយដែលត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាតែម្នាក់ឯងនោះឡើយ ខ. សហព្រះរាជអាជ្ញាអន្តរជាតិកំពុងតែជ្រៀតជ្រែកចូលទៅក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ ដោយព្យាយាមត្រួតត្រាទៅលើវិសាលភាពនៃការស៊ើបអង្កេតនេះ ក្រោមរូបភាពជា "[ការ]ដកចេញនូវភាពមិនច្បាស់លាស់ទាំងឡាយ" ហើយ គ. ការទទួលយកដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនេះ នឹងរំលោភលើសិទ្ធិជាមូលដ្ឋានរបស់លោក មាស មុត ក្នុងការទទួលការជំនុំជម្រះក្ដីដោយយុត្តិធម៌ នៅក្នុងពេលវេលាមួយសមស្រប" ("ញត្តិសុំលុបចោល")[4]។

## ខ. បណ្ដឹងឧទ្ធរណ៍

4. នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៥ មាស មុត បានដាក់ការជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំង "ការបដិសេធតាមការសន្មត" ចំពោះញត្តិសុំលុបចោលរបស់គាត់។ នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ មាស មុត បានដាក់បណ្ដឹងឧទ្ធរណ៍។ មាស មុត បានលើកទឡ្ហីករណ៍ថា ការដែលសហចៅក្រមស៊ើបអង្កេតមិនបានសម្រេចទៅលើញត្តិសុំលុបចោលរបស់គាត់ រយៈពេលបួនខែ បន្ទាប់ពីបានដាក់ គឺអាចចាត់ទុកថាជាការបដិសេធតាមការសន្មតចំពោះញត្តិដែលបានលើកឡើង ដោយសារតែការស៊ើបអង្កេតទៅលើបទឧក្រិដ្ឋកម្មថ្មី ពន្យារពេលការស៊ើបអង្កេតនេះ ហើយជាលទ្ធផលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប[5]។ មាស មុត បានលើកទឡ្ហីករណ៍ថា បណ្ដឹងឧទ្ធរណ៍អាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលជាមធ្យោបាយតែមួយគត់ក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់គាត់ នៅក្នុងពេលវេលាមួយសមស្រប[6]។ ជាជម្រើសមួយផ្សេងទៀត មាស មុត បានលើកទឡ្ហីករណ៍ថា អង្គបុរេជំនុំជម្រះអាចមានយុត្តាធិការទៅលើ

---

[4] ញត្តិរបស់មាស មុត ស្នើសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិ, ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤, ឯកសារ D120/1, កថាខណ្ឌផ្ដើម។

[5] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១២ ដល់១៧។

[6] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៨ ដល់១៩។



PRE-TRIAL CHAMBER E.C.C.C. CHAMBER

បណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើទៅលើវិធាន ៧៣(ខ) នៃវិធានផ្ទៃក្នុង ដែលផ្តល់អង្គជំនុំជម្រះនូវយុត្តាធិការលើពាក្យសុំមោឃភាពកិច្ចស៊ើបអង្កេត ដោយសារតែញត្តិសុំលុបចោលព្យាយាមមោឃភាព "ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលមានវិការផ្នែកនីតិវិធី"[7]។ ដូច្នេះ មាស មុត ស្នើអង្គបុរេជំនុំជម្រះឲ្យ ១) ទទួលយកបណ្តឹងឧទ្ធរណ៍ និង ២) បង្គាប់ដល់សហចៅក្រមស៊ើបអង្កេតឲ្យលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមចេញពីសំណុំរឿង[8]។

5. មិនមានការដាក់ចម្លើយតបណាមួយចំពោះបណ្តឹងឧទ្ធរណ៍នេះ នៅក្នុងពេលវេលាកំណត់ដែលមានជាធរមានឡើយ។

## គ. ភាពអាចទទួលយកបាន

6. មាស មុត មិនជំទាស់ទៅលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតឡើយ ប៉ុន្តែបានជំទាស់ថា ការពន្យាពេលសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះញត្តិសុំលុបចោលរបស់គាត់ បង្កើតបានជាការបដិសេធតាមការសន្មតទៅលើញត្តិដែលបានលើកឡើង ហើយបើកលទ្ធភាពឲ្យប្តឹងឧទ្ធរណ៍។ អង្គបុរេជំនុំជម្រះរម្លឹកថា អនុលោមតាមវិធាន ៧៣ និង ៧៤ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះមានយុត្តាធិការក្នុងការស្តាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "សេចក្តីសម្រេច" ឬ "ដីកា" ដែលចេញដោយសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែ អង្គបុរេជំនុំជម្រះបានសម្រេចនាពេលកន្លងមកថា សំណើដែលបានដាក់ដោយភាគី ហើយដែលនៅមិនទាន់ត្រូវបានសម្រេចដោយសហចៅក្រមស៊ើបអង្កេត អាចចាត់ទុកថាត្រូវបានបដិសេធ នៅពេលដែលសហចៅក្រមស៊ើបអង្កេត (១) មិនបានចេញសេចក្តីសម្រេចក្នុងពេលវេលាដែលបានកំណត់តាមផ្លូវច្បាប់ ប្រសិនបើមានពេលវេលាកំណត់ ឬ (២) ពន្យារពេលចេញសេចក្តីសម្រេចរបស់ខ្លួន ដើម្បីដកហូតពីភាគីនូវលទ្ធភាពក្នុងការទទួលបានផលប្រយោជន៍ដែលខ្លួនចង់បាន[9]។ នៅពេលដែលសំណើ ឬពាក្យសុំ

---

[7] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២០។

[8] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២២។

[9] សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០២") (អបជ១០) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អៀង សារី ពាក់ព័ន្ធការតែងតាំងអ្នកជំនាញវិកលវិទ្យា, ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨, ឯកសារ A189/I/8 ("សេចក្តីសម្រេចលើការតែងតាំងអ្នកជំនាញ"), កថាខណ្ឌ ២២ ដល់២៤។ សូមមើលផងដែរ , ឧទាហរណ៍ សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤") (អបជ១២), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងការ

មួយត្រូវបានចាត់ទុកថាត្រូវបានសហចៅក្រមស៊ើបអង្កេតបដិសេធ ភាគីដែលស្នើសុំអាចស្នើមកអង្គបុរេជំនុំជម្រះ ប្រសិនបើបញ្ហានោះស្ថិតក្នុងវិសាលភាពនៃយុត្តាធិការលើរឿងក្តីរបស់អង្គបុរេជំនុំជម្រះ[10]។

7. ក្នុងករណីដែលវិធានមិនបានចែងពីពេលវេលាកំណត់សម្រាប់ការចេញសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដូចជាករណីនេះ គ្រាន់តែការពន្យារពេលក្នុងការពិចារណាទៅលើសំណើ មិនបង្កើតបានជាការបដិសេធតាមការសន្មតឡើយ។ ដើម្បីអាចបកស្រាយភាពអសកម្មរបស់សហចៅក្រមស៊ើបអង្កេតថាជាការបដិសេធនោះ ចាំបាច់ត្រូវតែបង្ហាញឱ្យឃើញថា តាមលក្ខណៈនៃសំណើ សំណើនេះតម្រូវឱ្យមានការ "យកចិត្តទុកដាក់ឱ្យបានឆាប់ចត់" បើមិនដូច្នេះទេ សំណើនេះនឹងក្លាយទៅជាឥតន័យ[11]។ ដូចដែលអង្គជំនុំជម្រះបានរម្លឹកក្នុងពេលថ្មីៗនេះ "ទ្រឹស្តីនៃការបដិសេធតាមការសន្មតដែលអង្គជំនុំជម្រះបានអនុវត្តសម្រាប់កាលៈទេសៈពិសេសទាំងឡាយ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតមិនមានសកម្មភាព ឬការពន្យារពេលវេលាក្នុងការបំពេញកិច្ច អាចបណ្តាលឱ្យមានព្យសនកម្ម"[12]។ តាមពិតទៅ ករណីតែមួយគត់ដែលអង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មត ពាក់ព័ន្ធនឹងសំណើសុំតែងតាំងអ្នកជំនាញវិកលវិទ្យា ដើម្បីវាយតម្លៃលើសម្បទារបស់ អៀង សារី ក្នុងការចូលរួមក្នុងការ

---

បដិសេធតាមការសន្មត ចំពោះសំណើលើកទីបួនរបស់តា អាន សុំបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចលើសំណើលើកទីបួនរបស់ តា អាន"), កថាខណ្ឌ ៨។ អបជ ១០, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មាស មុត ប្រឆាំងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត ចំពោះសំណើលើកទី១៤ របស់មាស មុត ដាក់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D87/2/2 ("សេចក្តីសម្រេចលើសំណើលើកទី១៤ របស់ មាស មុត"), កថាខណ្ឌ ១០-១១។សំណុំរឿង ០០២ (អបជ ៤៦), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចរបស់ក.ស.ច.ស លើសំណើ D153, D172, D173, D174, D178 & D284 (សំណើលើកទី១២ របស់ខ្លួន ជា សុំបំពេញកិច្ចស៊ើបសួរ), ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារ D300/1/5, កថាខណ្ឌ ២០។

[10] សូមមើល, ឧទាហរណ៍, សំណុំរឿង ០០២ (អបជ២៨), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងការបដិសេធតាមការសន្មត របស់សហចៅក្រមស៊ើបអង្កេត ចំពោះសំណើលើកទីបីរបស់ អៀង សារី សុំបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៩, ឯកសារ D171/4/5, កថាខណ្ឌ ៩។

[11] សូមមើលសេចក្តីសម្រេចលើការតែងតាំងអ្នកជំនាញ, កថាខណ្ឌ ១៨ ដល់២៥។

[12] សេចក្តីសម្រេចលើសំណើលើកទីបួនរបស់ តា អាន, កថាខណ្ឌ ១១។

ការពារក្ដីរបស់គាត់ ដែលសហចៅក្រមស៊ើបអង្កេតបានពន្យារពេលទៅដំណាក់កាលក្រោយទៀតនៃកិច្ចដំណើរការនីតិវិធី។ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការពន្យារការពិចារណារបស់ខ្លួនទៅលើសំណើ អាចចាត់ទុកថាជាការបដិសេធតាមការសន្មត ដោយសារតែបញ្ហាជាមូលដ្ឋាន ដូចជា ការឃុំខ្លួនបណ្ដោះអាសន្ន និងការជំទាស់លើយុត្តាធិការ កំពុងត្រូវបានសម្រេច ហើយសហមេធាវីរបស់ អៀង សារី បានលើកទឡ្ហីករណ៍ថា គាត់ប្រហែលជាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់នេះទេ[13]។ ការព្យាយាមថែមទៀតទាំងអស់ក្នុងការស្នើមកអង្គបុរេជំនុំជម្រះ ដោយមិនទាន់មានសេចក្ដីសម្រេចចេញពីសហចៅក្រមស៊ើបអង្កេតជាមុន មិនទទួលបានជោគជ័យឡើយ។ ជាពិសេស អង្គបុរេជំនុំជម្រះយល់ឃើញថា មិនមានការបដិសេធតាមការសន្មតទេ ប្រសិនបើ ១) វិធាននីតិវិធីជាធរមានមិនបានប្រមើលមើលលើសេចក្ដីសម្រេចចំពោះបញ្ហានេះ នៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធីទេ ហើយបញ្ហានេះអាចត្រូវបានលើកយកមកដាក់នៅចំពោះមុខអង្គ ជំនុំជម្រះនៅពេលក្រោយ ដោយមិនរំលោភបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ម្ចាស់បណ្ដឹងសាទុក្ខ (ឧទាហរណ៍ បញ្ហាដែលត្រូវដោះស្រាយនៅក្នុងដីកា ដំណោះស្រាយ ប៉ុន្តែភាគីនោះព្យាយាមដោះស្រាយជាមុន តាមរយៈសំណើសុំការបញ្ជាក់)[14] ២) ម្ចាស់បណ្ដឹងឧទ្ធរណ៍ "មិនបានបង្ហាញថា សិទ្ធិដែលបានអះអាងរបស់គាត់ កំពុងរងហានិភ័យនៃការប៉ះពាល់ដែលមិនអាចទូទាត់សងបាន"[15] ៣) វិធានផ្ដល់ដំណោះស្រាយសមស្របមួយ ដែលនឹងនៅតែអាចយកប្រើ

---

[13] សេចក្ដីសម្រេចលើការតែងតាំងអ្នកជំនាញ, កថាខណ្ឌ ១៨ ដល់២៥។ សូមមើលផងដែរ កថាខណ្ឌ ១៤ ដល់១៧ ដែលអង្គបុរេជំនុំជម្រះបានពិភាក្សាពីយុត្តាធិការលើរឿងក្ដីរបស់ខ្លួន ចំពោះបណ្ដឹងឧទ្ធរណ៍។

[14] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះសារណារបស់អៀង សារី ប្រឆាំងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ, ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ D345/5/11 ("សេចក្ដីសម្រេចលើដីកាសម្រេចអំពីការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ"), កថាខណ្ឌ ១១។ សូមមើលផងដែរ សេចក្ដីសម្រេចលើសារណាលើកទី១៤ របស់មាស មុត, កថាខណ្ឌ ៣៤។

[15] សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤") (អបជ ១៧), សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងការបដិសេធតាមការសន្មត របស់សហចៅក្រមស៊ើបអង្កេត ចំពោះសំណើរបស់គាត់ សុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ធ្វើការពិចារណាទៅលើការដាក់បង្ហាញ កំណត់ហេតុស្ដាប់ចម្លើយសាក្សីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២, ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥, ឯកសារលេខ D229/1/2 ("សេចក្ដីសម្រេចលើការដាក់បង្ហាញ"), កថាខណ្ឌ ៨។



PRE-TRIAL CHAMBER E.C.C.C.

នៅដំណាក់កាលក្រោយទៀត ដើម្បីដោះស្រាយការចោទប្រកាន់អំពីការរំលោភបំពានលើសិទ្ធិ ឬភាពមិនប្រក្រតីក្នុងកិច្ចស៊ើបអង្កេត ដូច្នេះហើយសិទ្ធិក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ អាចត្រូវបានការពារយ៉ាងគ្រប់គ្រាន់ដោយក្របខណ្ឌច្បាប់ដែលមានស្រាប់ (ឧទាហរណ៍ លទ្ធភាពក្នុងការដាក់សំណើសុំមោឃភាព អនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង)[16] ៤) សហចៅក្រមស៊ើបអង្កេតបានបង្ហាញថា ពួកគាត់កំពុងពិចារណាលើសំណើ ឬពាក្យសុំ[17] និង៥)សហចៅក្រមស៊ើបអង្កេតបានផ្ដល់ហេតុផលសមស្របចំពោះការពន្យារពេលរបស់ពួកគាត់ក្នុងការសម្រេចទៅលើបញ្ហានេះ[18]។

8. នៅក្នុងករណីបច្ចុប្បន្ននេះ មាស មុត បានលើកទឡ្ហីករណ៍ថា ការពន្យារពេលចេញសេចក្ដីសម្រេចលើញត្តិសុំលុបចោលរបស់គាត់ បានដកហូតផលប្រយោជន៍ដែលគាត់ស្វះស្វែងរក គឺការលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចេញពីក្នុងសំណុំរឿងភ្លាមៗ ដោយផ្អែកលើមូលដ្ឋានដែលថា ការបន្ថែមបទឧក្រិដ្ឋថ្មីៗ និងពន្យារពេលបន្ថែមទៀតដល់កិច្ចស៊ើបសួរតាមផ្លូវតុលាការ ព្រមទាំងរំលោភលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប[19]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីជា មាស មុត ព្យាយាមទទួលបាននូវដំណោះស្រាយភ្លាមៗក៏ដោយ ការពន្យារពេលរបស់សហចៅក្រមស៊ើបអង្កេតក្នុងការពិចារណាទៅលើញត្តិសុំលុបចោល មិនបង្កើតបានជាការបដិសេធតាមការសន្មតឡើយ ដោយផ្អែកលើសំអាងហេតុចំនួនពីរ។

---

[16] សេចក្ដីសម្រេចលើសំណើចំនួន១៤របស់ មាស មុត, កថាខណ្ឌ ២០, ៣២។ សូមមើលផងដែរ សំណុំរឿង ០០២ (អបជ៣១), សេចក្ដីសម្រេចលើភាពអាចទទួលយកបាន នៃបណ្ដឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស ចំពោះសំណើរបស់អៀង សារី ពាក់ព័ន្ធការកំណត់អត្តសញ្ញាណរបស់ ក.ស.ច.ស និងភាពអាចជឿជាក់បានទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម, ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៩, ឯកសារ D130/7/3/5, កថាខណ្ឌ ២៦-៣៩។

[17] សំណុំរឿង ០០៣ (អបជ១០), សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់មាស មុត ប្រឆាំងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើរបស់មាស មុត សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៥, ឯកសារ D87/2/3, កថាខណ្ឌ ១០-១១។

[18] សេចក្ដីសម្រេចលើសំណើទាំង១៤របស់ មាស មុត, កថាខណ្ឌ ១២-១៣។

[19] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៣ ដល់១៥។

01108448



9. ទីមួយ កំណត់ត្រាបង្ហាញច្បាស់ថា សហចៅក្រមស៊ើបអង្កេតមិនបានបដិសេធលើញត្តិសុំលុបចោលឡើយ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យារពេលក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន រហូតដល់ពេល មាស មុត ក្លាយជាភាគីនៃកិច្ចដំណើរការនីតិវិធី ដូច្នេះហើយ គាត់នឹងត្រូវបានអនុញ្ញាតឲ្យដាក់សារណានៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ញត្តិត្រូវបានដាក់នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ នៅពេលនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងធ្វើការសម្រេចទៅលើឋានៈផ្លូវច្បាប់របស់ មាស មុត អនុលោមតាមវិធានផ្ទៃក្នុង និងសិទ្ធិរបស់គាត់ក្នុងការដាក់សារណានៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដោយសារតែគាត់មិនត្រូវបានចោទប្រកាន់ជាផ្លូវការ តាមនីតិវិធីដែលមានចែងក្នុងវិធាន ៥៧ នៃវិធានផ្ទៃក្នុង[20]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ជនសង្ស័យដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលមិនទាន់ត្រូវបានចោទប្រកាន់ អនុលោមតាមវិធាន ៥៧ នៃវិធានផ្ទៃក្នុង មិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធីទេ ដូច្នេះ មិនត្រូវបានអនុញ្ញាតឲ្យដាក់សារណានៅចំពោះមុខសហចៅក្រមស៊ើបអង្កេតឡើយ លើកលែងតែក្នុងករណីគាត់អាចផ្តល់យុត្តិកម្មអំពីផលប្រយោជន៍ជាពិសេសមួយក្នុងនាមជា "ជនសង្ស័យ"[21]។ គោលជំហរនេះត្រូវបានជំទាស់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ប៉ុន្តែ នៅតែមានអានុភាពចងកាតព្វកិច្ច ដោយសារតែអង្គបុរេជំនុំជម្រះមិនអាចស្វែងរកបានសម្លេងភាគច្រើន បួនសម្លេង ដើម្បីសម្រេចលើបញ្ហានេះ[22]។ ស្ថានភាពបានប្រែប្រួលនៅថ្ងៃទី ០៣ ខែ

---

[20] ការជូនដំណឹងទាក់ទងសំណើរបស់ជនសង្ស័យ សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ (ឯកសារ D82) និងស្នើសុំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទាំងស្រុង និងឯកសារគាំទ្រនានា (ឯកសារ D82/2), ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤, ឯកសារ D82/3, កថាខណ្ឌ ១៦។ សេចក្តីសម្រេចលើសំណើរបស់មាស មុត សុំដាក់សារណាទាំងអស់ទៅក្នុងសំណុំរឿង, ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤, ឯកសារ D108/1, កថាខណ្ឌ ៣។ សូមមើលផងដែរ ការជូនដំណឹងអំពីសំណើរបស់ជនសង្ស័យ សុំចូលពិនិត្យមើលសំណុំរឿង ចូលរួមក្នុងកិច្ចស៊ើបសួរ និងសុំលប់ចោលសារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ, ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤, ឯកសារ D82/5, កថាខណ្ឌ ១៦-១៧។

[21] សូមមើល, ឧទាហរណ៍,សំណុំរឿង ០០៤, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី តា អាន សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣, ឯកសារ D121/4។

[22] សូមមើលសំណុំរឿង ០០៤ (អបជ០៥), ការពិចារណារបស់អង្គជំនុំជម្រះទៅលើ បណ្តឹងឧទ្ធរណ៍របស់តា អាន ប្រឆាំងសេចក្តីសម្រេចបដិសេធ សំណើរបស់គាត់សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤, ឯកសារ D121/4/1/4។ សូមមើលផងដែរ ,អំពីឋានៈផ្លូវច្បាប់របស់ មាស មុត, អបជ ១៥, ការពិចារណារបស់អង្គបុរេ

មីនា ឆ្នាំ ២០១៥ នៅពេលដែល មាស មុត ត្រូវបានចោទប្រកាន់ជាផ្លូវការចំពោះបទឧក្រិដ្ឋកម្មមួយចំនួន ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងត្រូវបានជូនដំណឹងថា ឥឡូវនេះ គាត់គឺជាភាគីនៃកិច្ចដំណើរការនីតិវិធី ហើយត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ[23]។ នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥ មាស មុត បានស្នើដល់សហចៅក្រមស៊ើបអង្កេតឱ្យដោះស្រាយសារណាមួយចំនួនរបស់គាត់ដែលនៅមិនទាន់បានដោះស្រាយ ប៉ុន្តែ សំណើរបស់គាត់មិនបានរួមបញ្ចូលញត្តិសុំលុបចោលនោះឡើយ[24]។ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងនៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ថា ដោយសារតែមានការផ្លាស់ប្តូរនៃឋានៈផ្លូវច្បាប់របស់ មាស មុត សហចៅក្រមស៊ើបអង្កេត ក្នុងពេលនោះ កំពុងធ្វើការពិចារណាទៅលើសារណារបស់ មាស មុត ដែលមិនទាន់បានសម្រេច[25]។ ទោះបីជាញត្តិសុំលុបចោលមិនត្រូវបានលើកឡើងបញ្ជាក់ក៏ដោយ មានការរំពឹងថា ញត្តិនេះនឹងត្រូវបានពិចារណាផងដែរនៅក្នុងពេលអនាគតឆាប់ៗនេះ។

10. ទីពីរ មាស មុត មិនបានបង្ហាញថា ការពន្យារពេលចេញសេចក្តីសម្រេចទៅលើញត្តិសុំលុបចោលរបស់គាត់ ទីបំផុត នឹងដកហូតជាពីគាត់នូវផលប្រយោជន៍ដែលគាត់បានស្វែងរកទេ។ កិច្ចដំណើរការនីតិវិធីដែលត្រូវបានចាត់ទុកថាជាមោឃៈ អាចត្រូវបានមោឃភាព ហើយត្រូវដកចេញពីសំណុំរឿង រហូតដល់ពេលមានការចេញដីកាដំណោះស្រាយ[26]។ ហេតុដូច្នេះ ដំណោះស្រាយដែលសមស្របនៅតែមាន នៅដំណាក់កាលក្រោយទៀត ដើម្បីដកដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចេញពីក្នុងសំណុំរឿង ប្រសិនបើរកឃើញថា ដីកាសន្និដ្ឋាននេះគ្មានសុពលភាព។ ទទ្បីករណ៍របស់

---

ជំនុំជម្រះ ទៅលើបណ្តឹងឧទ្ធរណ៍របស់មាស មុត ប្រឆាំងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត មិនដាក់ជូនអង្គបុរេជំនុំជម្រះ សំណើសុំមោឃភាពចំនួនពីរ, ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥, ឯកសារ D103/5/2។

[23] សេចក្តីសម្រេចចោទប្រកាន់មាស មុត កំបាំងមុខ, ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ D128។ ឧបសម្ព័ន្ធ, ការជូនដំណឹងអំពីបទចោទប្រឆាំងមាស មុត, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ D128.1។

[24] សំណើរបស់មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេត បំពេញកិច្ចតាមសំណើរបស់គាត់កន្លងមក, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ D132។

[25] ចម្លើយតបចំពោះសំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេត បំពេញកិច្ចតាមសំណើរបស់គាត់កន្លងមក, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥, ឯកសារ D132/1។

[26] វិធាន ៧៦(២) នៃវិធានផ្ទៃក្នុង។

មាស មុត ដែលថា ការអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះ គឺជាការចាំបាច់នៅដំណាក់កាលនេះ ដើម្បីទប់ស្កាត់ការរំលោភបំពានទៅលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប ដែលថា ដូច្នេះហើយមានហេតុផលគ្រប់គ្រាន់ ក្នុងការទទួលយកបណ្តឹងឧទ្ធរណ៍នេះ មិនគួរឱ្យជឿទេ។ គួរបញ្ជាក់ថា នៅពេលមិនទាន់មានសេចក្តីសម្រេចណាមួយទៅលើបញ្ហានេះ អង្គបុរេជំនុំជម្រះអាចទទួលយកបញ្ហានេះមកដោះស្រាយ តែក្នុងករណីដែលកាលៈទេសៈនៃសំណុំរឿងអាចឱ្យមានការសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេត ជាក់ស្តែង បានបដិសេធសំណើដែលបានដាក់ជូនគាត់។ ការដែលថា ការពន្យារពេលពិចារណាទៅលើសំណើ អាចនឹងពន្យារពេលដល់ការស៊ើបអង្កេត មិនបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតបានច្រានចោលសំណើនោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការស៊ើបអង្កេតកំពុងត្រូវបានធ្វើទៅលើការចោទប្រកាន់លើអង្គហេតុមួយចំនួន ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយមិនមានការបង្ហាញនៅដំណាក់កាលនេះ ថា មានការពន្យារពេលដោយសារតែការស៊ើបអង្កេតទៅលើបទឧក្រិដ្ឋបន្ថែមដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឡើយ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

**បដិសេធបណ្តឹងឧទ្ធរណ៍** ដោយចាត់ទុកថាមិនអាចទទួលយកបាន។

**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គីមសាន** **Olivier BEAUVALLET** **នេយ ថុល** **Steven J. BWANA** **ហួត វុទ្ធី**